## ខេត្តស្វាយរៀង

## សក្តានុពលវិនិយោគ

ឧសភា ឆ្នាំ ២០០៨




# ខេត្តស្វាយរៀង

## មានប្រជាជន ១២ លាននាក់ នៅច្រកចេញចូលរបស់អ្នក










USAID
ជំនួយពីពលរដ្ឋអាមេរិក

**បញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពី ទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកនោះទេ។




# របាយការណ៍វិនិយោគនៅខេត្តស្វាយរៀង


**មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត** ______ ២

**ចំណុចខ្លាំងរបស់ប្រទេស** ______ ៣

បរិយាកាសអាជីវកម្មបើកចំហ
កម្លាំងពលកម្មដែលមានតំលៃឈ្នួលពលកម្មទាប
ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

**តើហេតុអ្វីជ្រើសរើសយកខេត្តស្វាយរៀង?** ______ ៤

១. ប្រទេសវៀតណាមនៅលើផ្លូវដើរចូលទៅកាន់ទ្វារមុខផ្ទះរបស់អ្នក
២. បរិយាកាសអាជីវកម្ម
៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខគេ
៤. សក្តានុពលលើវិស័យទេសចរណ៍
៥. កម្លាំងពលកម្មដែលមានការអប់រំ
៦. អគ្គិសនីមានលក្ខណៈប្រកួតប្រជែង និងអាចទុកចិត្តបាន

**ឱកាសអាជីវកម្ម** ______ ៧

**ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ** ______ ៧


របាយការណ៍វិនិយោគនេះផលិតដោយ EMC សំរាប់គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។









## មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត

ខេត្តស្វាយរៀង ដែលស្ថិតនៅភាគខាងត្បូងឈៀងខាងកើត នៃព្រំប្រទល់ប្រទេសកម្ពុជា និងវៀតណាម មានចំងាយតែ ៦០ គ.មគត់ ហើយធ្វើដំណើររយៈពេលមួយម៉ោងមកពីទីក្រុងហូជីមិញ និងមានចំងាយ ១២៥ គ.មពីទីក្រុងភ្នំពេញ ។ ចំនួនប្រជាជននៅក្នុងខេត្តនេះមានជាងកន្លះលាននាក់រស់នៅ ដែលក្នុងនោះប្រជាជន ១០ 000នាក់ ធ្វើការនៅក្នុងរោងចក្រ តំបន់ឧស្សាហកម្ម សណ្ឋាគារ និងសហគ្រាសដទៃទៀត ។

ពាណិជ្ជកម្មមួយចំនួនបានជ្រើសរើសមកដាក់ប្រតិបត្តិការរបស់ខ្លួននៅក្នុងខេត្តនេះដើម្បីទទួលបានផលប្រយោជន៍នៃឱកាសដ៏អស្ចារ្យដែលយើងបានផ្តល់ជូន ហើយខេត្តនេះមានទីតាំងនៅជិតបំផុតទៅនឹងទីផ្សារមួយក្នុងចំណោមទីផ្សារដែលលេចធ្លោ និងបង្កើតបានស្នាដៃច្រើនជាងគេនូវតំបន់អាស៊ី ។

យើងមានក្តីរំភើបចំពោះសក្តានុពលក្នុងការពង្រីក និងធ្វើឱ្យឧស្សាហកម្មរបស់យើងកាន់តែរីកចំរើនឡើង ដោយយើងបានរៀបចំឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ក្នុងការផ្តល់ទុនទៅឱ្យតំបន់យុទ្ធសាស្ត្ររបស់យើង។ ដូច្នេះហើយយើងសូមស្វាគមន៍ដោយបើកចំហចំពោះវិនិយោគិនថ្មីៗ ទាំងក្នុងស្រុក និងមកពីបរទេស ។ យើងបានបង្កឱ្យមានលក្ខណៈងាយស្រួលដល់វិនិយោគិនក្នុងការចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងបើកដំណើរការអាជីវកម្មរបស់ខ្លួន។ តំលៃវិនិយោគចូលក្នុងខេត្តស្វាយរៀង គឺស្ថិតក្នុងចំណោមតំលៃដែលទាបជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ហើយអាជ្ញាធរខេត្តរបស់យើងនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីជួយដល់វិនិយោគិនក្នុងការបង្កើតអាជីវកម្មរបស់ខ្លួន[1] ។

យើងក៏បានបង្កើតផងដែរនូវតំបន់សេដ្ឋកិច្ចពិសេសដោយផ្តល់ឱ្យនូវច្រកចេញចូលតែមួយសំរាប់ផ្តល់ការអនុញ្ញាតផ្នែករដ្ឋបាលទាំងអស់ ហេដ្ឋារចនាសម្ព័ន្ធសំរាប់ការដឹកជញ្ជូនដែលល្អប្រសើរ ព្រមទាំងការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបាននិងមានតំលៃថោក ។

តាមរយៈការអភិវឌ្ឍន៍ថ្មីៗទាំងនេះភាពខ្លាំងនៃធនធានធម្មជាតិរបស់យើងនិងកំលាំងពលកម្មដែលនៅក្មេងមានចំណេះដឹង មានកំលាំងរឹងមាំ និងឧស្សាហ៍ព្យាយាមក្នុងការងារក៏ដូចជាខេត្តស្វាយរៀងទាំងមូលមានលំនឹង សំរាប់ការរីកចំរើនគួរឱ្យកត់សំគាល់ ។ សូមអញ្ជើញមកវិនិយោគ និងចូលរួមក្នុងឱកាសដ៏គួរឱ្យរំភើបនេះ ។

ខ្ញុំសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិដែលបានជួយឧបត្ថម្ភក្នុងការរៀបចំបង្កើតរបាយការណ៍វិនិយោគនិងបានបន្តគាំទ្រលើការផ្សព្វផ្សាយការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តរបស់យើងខ្ញុំ។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយវិនិយោគិនទាំងអស់ ដើម្បីជួយធ្វើឱ្យអាជីវកម្មរបស់ពួកគេព្រមទាំងខេត្តដែលមានសក្តានុពលរបស់យើងនេះ កាន់តែមានភាពរីកចំរើនឡើងថែមទៀត ។

សូមទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ឯកឧត្តម ជៀង អំ**
អភិបាលខេត្តស្វាយរៀង

*1. ខេត្តស្វាយរៀងទទួលបានចំណាត់ថ្នាក់លេខមួយក្នុងចំណោមខេត្តដប់របស់កម្ពុជា ចំពោះការដើរតួយ៉ាងសកម្មរបស់អាជ្ញាធរខេត្ត ហើយទទួលបានចំណាត់ថ្នាក់លេខពីរ ចំពោះតំលៃវិនិយោគចូល ។ យើងទទួលបានចំណាត់ថ្នាក់លេខពីរ ចំពោះបរិយាកាសអាជីវកម្មទាំងមូល ។*





# ចំណុចខ្លាំងរបស់ប្រទេស

សំរាប់រយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានចេញមុខជាអ្នកប្រកួតប្រជែងក្នុងតំបន់ដ៏រឹងមាំនិងរហ័សរហួនដោយមានភោគទ្រព្យយ៉ាងសម្បូរបែបដែលមានសារៈសំខាន់បំផុតសំរាប់កំនើន និងការអភិវឌ្ឍន៍អាជីវកម្មប្រកបដោយជោគជ័យ ។

## បើកទូលាយសំរាប់អាជីវកម្ម

- ពន្ធលើប្រាក់ចំណេញដែលមានតម្លៃទាប – ពន្ធ ២០% លើប្រាក់ចំណេញ ( ការខាតបង់ ៥ ឆ្នាំទៅមុខ)
- ពុំមានការកំណត់លក្ខខណ្ឌកាន់កាប់បរទេសទេ ។ ប្រទេសកម្ពុជាអនុញ្ញាតឱ្យសម្ព័ន្ធអាជីវកម្មរួមគ្នា ឬក្រុមហ៊ុនដែលកាន់កាប់ដោយបរទេសប្រត្តិបត្តិការ ១០០% ដោយមានសិទ្ធិពេញលេញដែលអាចនាំចូល និងនាំចេញផលិតផលបានស្ទើរតែគ្រប់ប្រភេទ។
- វិនិយោគិនទាំងអស់ទទួលបានការការពារប្រកបដោយសមភាព ។
- ប្រទេសកម្ពុជាមានសេរីភាពខាងសេដ្ឋកិច្ចជាងប្រទេសចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី [2] ។
- ពុំមានការគ្រប់គ្រងតម្លៃនៃផលិតផល ឬសេវាណាមួយទេ ។
- ពុំមានការគ្រប់គ្រងការប្តូររូបិយប័ណ្ណបរទេស ឬការកំណត់លក្ខខណ្ឌទៅលើការប្តូររូបិយប័ណ្ណនេះទេ ។
- ពុំមានការកំណត់លក្ខខណ្ឌស្តីពីការបង្វិលទុនទេ ។
- សមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន។
- ពុំមានការកំណត់លក្ខខណ្ឌអាជីវកម្មបរិមាណ និងពុំមានការទំលាក់ថ្លៃរបាំងពន្ធគយ។ ប្រទេសកម្ពុជាអាចទទួលបានការលើកលែងពន្ធ និងការកំណត់កូតានៅលើទីផ្សារពិភពលោកធំៗ (ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ជប៉ុន និងបណ្តាប្រទេសសមាជិកអាស៊ានជាច្រើនទៀត ) ។
- អាជ្ញាធរខេត្តមានសិទ្ធិអនុម័តការវិនិយោគទុនក្រោម ២ លានដុល្លារ ដើម្បីការចាប់ផ្តើមអភិវឌ្ឍន៍ពាណិជ្ជកម្មឆាប់រហ័ស ។

*"ប្រទេសកម្ពុជា បើកទូលាយយ៉ាងពេញលេញសំរាប់ពាណិជ្ជកម្ម ហើយរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា នឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធានានូវបរិយាកាសគួរជាទីពេញចិត្ត និងជោគជ័យដល់គ្រប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។"*

– សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន – នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

2.*The Heritage Foundation* លិបិក្រមនៃសេរីភាពសេដ្ឋកិច្ច ឆ្នាំ២០០៨ ។ *http://www.heritage.org/index/*

## កំលាំងពលកម្មដែលមានតម្លៃទាប

បើប្រៀបធៀបទៅនឹងដៃគូប្រកួតប្រជែងជាច្រើនក្នុងតំបន់ ប្រទេសកម្ពុជារីករាយនឹងទទួលយកអត្រាប្រាក់ឈ្នួលទាបសមរម្យ ក្នុងគោលដៅទាក់ទាញឧស្សាហកម្មដែលប្រើកំលាំងពលកម្មច្រើន ។

ឆ្លងកាត់ជាច្រើនឆ្នាំចុងក្រោយនេះ កំលាំងពលកម្មនៅប្រទេសកម្ពុជាបានកើនឡើងជាង ៥០% ច្រើនជាងពីរដង នៃអត្រានៅក្នុងប្រទេសសមាជិកអាស៊ានផ្សេងទៀត[3] ។ ហើយដោយសារមានចំនួនប្រជាជនវ័យក្មេងច្រើន (ដែលចំនួនពាក់កណ្តាលមានអាយុក្រោម២០ ឆ្នាំ) ធ្វើឱ្យកំនើននៃកំលាំងពលកម្មនេះ នឹងបន្តកើនឡើង ។

## ប្រាក់ឈ្នួលក្នុងឧស្សាហកម្មកាត់ដេរ[4]

| ប្រទេស | អត្រាប្រាក់ឈ្នួលក្នុងមួយម៉ោង (US$) |
|---|---|
| កម្ពុជា | 0.33 |
| ចិន | 0.88[a]/0.66[b] |
| ប៉ាគីស្ថាន | 0.41 |
| ឥណ្ឌា | 0.38 |
| ឥណ្ឌូនេស៊ី | 0.30 |
| បង់ក្លាដេស | 0.39 |

## ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងនៅចំកណ្តាលតំបន់ដែលមានសក្តានុពលបំផុតនៅលើពិភពលោក។ នៅប្រទេសថៃ និងប្រទេសវៀតណាម ប្រទេសកម្ពុជាគឺជាផ្នែកមួយនៃច្រកសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ ដែលលាតសន្ធឹងចេញពីទីក្រុងហូជីមិញរហូតដល់ទីក្រុងបាងកក ។

ដោយសារទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន ប្រទេសកម្ពុជាបានរីករាយ នឹងទទួលយកការគាំទ្រអន្តរជាតិដ៏សំខាន់ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនរបស់ខ្លួនដើម្បីសម្រួលដល់ពាណិជ្ជកម្មក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផល ពាណិជ្ជកម្មជាមួយ នឹងប្រទេសវៀតណាម និងប្រទេសថៃកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស ។

3. ILO, *"និន្នាការសង្គម និងពលកម្មនៅក្នុងអាស៊ាន ឆ្នាំ ២០០៧ – សមាហរណកម្ម បញ្ហាប្រឈម និងឱកាស " ឆ្នាំ ២០០៧ ។*

4. *ចំណាំៈ a ) តំបន់ឆ្នេរ b ) តំបន់ដីគោក*

*ប្រភពៈ បាហ្គាវី (Bargawi) " ឧស្សាហកម្មកាត់ដេរកម្ពុជា –ប្រភព និងការរំពឹង ទុកពេលអនាគត" វិទ្យាស្ថានអភិវឌ្ឍការគ្រប់គ្រង ឆ្នាំ ២០០៥ ។*








*"អ្នកមានទីក្រុងធំជាងគេចំនួនពីរនៅក្នុងអាស៊ីនៅអមប្រទេសអ្នក ។ អ្នកមានប្រជាជន១៥ លាននាក់នៅទីក្រុងបាងកក និង ៨លាននាក់ នៅទីក្រុងហូជីមិញ ហើយកំណើនផ្សេងៗ មានការកើនឡើងជាលំដាប់ នៅកណ្ដាលនៃទីក្រុងទាំងពីរ ។"*

- Edward Hopkins, CB Richard Ellis Group Inc.

# តើហេតុអ្វីជ្រើសរើសយកខេត្តស្វាយរៀង?

## ១. ប្រទេសវៀតណាមនៅលើផ្លូវដើរចូលទៅកាន់ទ្វារមុខផ្ទះរបស់អ្នក

ខេត្តស្វាយរៀងមានទីតាំងស្ថិតនៅលើផ្លូវពាណិជ្ជកម្មសំខាន់ នៅចន្លោះ ទីក្រុងហូជីមិញ និង ទីក្រុងភ្នំពេញ។ ខេត្តនេះមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម ហើយទៅហូជីមិញ បើកបររយៈពេលតែ ១ ម៉ោងទេ (រយៈពេល ១ម៉ោងកន្លះ ពីទីរួមខេត្តស្វាយរៀង)។ ពីភ្នំពេញមកបើកបររយៈពេល ២ ម៉ោងកន្លះ[5]។ ដូច្នេះ យើងមានការធ្វើដំណើររយៈពេលយ៉ាងខ្លីទៅកាន់ទីផ្សារដែលមានសក្ដានុពលជាងគេពីរនៅក្នុងអាស៊ី ដែលមានអ្នកប្រើប្រាស់ផលិតផល ចំនួនជាង ១២ លាននាក់ និងអាជីវកម្ម ចំនួន ៣៥0,000 ។

ដោយមានទីតាំងនៅជិត និងមានព្រំប្រទល់ជាប់ជាមួយនឹងប្រទេសវៀតណាមផងនោះ ទើបខេត្តនេះទទួលបានការដាក់លក់ផលិតផលរបស់ខេត្តនៅលើទីផ្សារដ៏ធំមួយ ។ ដើម្បីពង្រឹងអត្ថប្រយោជន៍ជាយុទ្ធសាស្ត្រនេះ សំរាប់អាជីវកម្មខេត្ត យើងបានបង្កើតកន្លែងត្រួតពិនិត្យអន្តរជាតិ ចំនួនពីរកន្លែងនៅក្នុងខេត្តស្វាយរៀង ហើយយើងបានធ្វើផែនការបានមួយភាគបីហើយ ។ ពាណិជ្ជកម្មឆ្លងដែននៅក្នុងព្រំប្រទល់តែមួយ មានសកម្មភាពរស់រវើកណាស់ ។ ខេត្តនេះមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រសើរផងដែរ ដោយផ្ដល់នូវភាពងាយស្រួលចំពោះការចូលទៅកាន់ទីផ្សារនាំចេញ និងនៅក្នុងស្រុក ។

ខេត្តស្វាយរៀងមានផ្លូវជាតិពីរខ្សែប្រវែង ១២៧ គីឡូម៉ែត្រ ។ ខេត្តនេះមានផ្លូវជាតិជាច្រើនគីឡូម៉ែត្រ ដែលក្នុងមួយគីឡូម៉ែត្រការ៉េ (៤.៣ គ.ម) ទំហំធំជាងផ្លូវជាតិទូទាំងប្រទេសគិតជាមធ្យមពីរដង។ បណ្ដាញផ្លូវគោករបស់យើងរលោង លឿន និងថែទាំបានល្អ។ ផ្លូវជាតិលេខ ១ កាត់តាមខេត្តនេះពីភ្នំពេញទៅហូជីមិញ ។ ដោយសារការទទួលស្គាល់ថាជាផ្នែកមួយនៃបណ្ដាញផ្លូវអាស៊ាន ដែលមានសារៈសំខាន់នៅក្នុងសមាហរណកម្ម សេដ្ឋកិច្ចតំបន់យើងធានាផ្ដល់នូវការអភិវឌ្ឍន៍ និងបរិមាណផលិតផល តាមរយៈច្រកនេះឱ្យកាន់តែប្រសើរឡើង ។

## ២. បរិយាកាសគាំទ្រអាជីវកម្ម

បរិយាកាសអាជីវកម្មខេត្តស្វាយរៀង ជាបរិយាកាសល្អមួយក្នុងចំណោមបរិយាកាសល្អបំផុតរបស់ប្រទេសកម្ពុជា ។ យើងបានបង្កើតអនុគណៈកម្មាធិការវិនិយោគមួយ និងអគ្គលេខាធិការដ្ឋាន ដើម្បីសម្រួលដល់ការវិនិយោគទុនក្នុងវិស័យឯកជន ។

ថ្មីៗនេះ ខេត្តស្វាយរៀងបានទទួលបានចំណាត់ថ្នាក់លេខ ២ ក្នុងចំណោមខេត្តនានារបស់កម្ពុជា ដោយសារបរិយាកាសគាំទ្រដល់អាជីវកម្មរបស់ខេត្តនេះ ។ នៅខេត្តស្វាយរៀង យើងធ្វើគ្រប់បែបយ៉ាងតាមដែលយើងអាចធ្វើបាន ដើម្បីផ្ដល់នូវបរិយាកាសសុវត្ថិភាព និងមានសក្ដានុពលសំរាប់អាជីវកម្មរបស់អ្នក ។

ចំណាត់ថ្នាក់របស់យើង ទទួលបានតាមរយៈតារាងវាយតម្លៃ បរិយាកាសអាជីវកម្មតាមខេត្តឆ្នាំ២00៦ របស់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ - មូលនិធិអាស៊ី (PBES)[6] ។ តារាងវាយតម្លៃនេះធ្វើការវាស់វែង ទៅលើការគ្រប់គ្រងសេដ្ឋកិច្ច និងគោលនយោបាយច្បាប់ដោយសារមានការពាក់ព័ន្ធទៅនឹងការគាំទ្រដល់បរិយាកាសពាណិជ្ជកម្មយ៉ាងសកម្ម និងផុសផុល ។

ជាពិសេស ការវាយតម្លៃបង្ហាញថា **ខេត្តស្វាយរៀងមាន:**

### អាជ្ញាធរខេត្តដែលមានសកម្មភាពគាំទ្របំផុតនៅកម្ពុជា

ខេត្តស្វាយរៀងទទួលបានចំណាត់ថ្នាក់លេខមួយ ផ្នែកសកម្មភាពគាំទ្ររបស់អាជ្ញាធរខេត្តនេះចំពោះការគាំទ្រអាជីវកម្មនៅក្នុងខេត្ត និងការធ្វើឱ្យបរិយាកាសអាជីវកម្មកាន់តែមានភាពប្រសើរថែមទៀត។ ក្នុងន័យនេះមានន័យថា ខេត្តរបស់យើងមានកិរិតសក្ដានុពលខ្ពស់ជាងគេទូទាំងប្រទេសកម្ពុជា ។

ឥរិយាបថរបស់មន្ត្រីយើងចំពោះអាជីវកម្មឯកជនគឺវិជ្ជមាន។ យើងសហការជាមួយច្បាប់កណ្ដាល ដើម្បីបង្កើតបរិយាកាសអាជីវកម្ម ដែលអាចទាញយកផលកម្រៃបាន ។ យើងបង្ហាញពីការច្នៃប្រឌិត និងគំនិតក្នុងការដោះស្រាយបញ្ហាអាជីវកម្មថ្មីៗ ។

| សូចនាករអំពីសកម្មភាពគាំទ្រដែលជ្រើសរើស | ក្រុមហ៊ុន |
|---|---|
| អាជ្ញាធរខេត្តមានគំនិតច្នៃប្រឌិត និងឆ្លាតវៃក្នុងការដោះស្រាយបញ្ហាក្រុមហ៊ុន ។ | 76% |
| អាជ្ញាធរខេត្តពូកែខាងសហការជាមួយច្បាប់កណ្ដាល | 83% |

5. *រយៈពេលបើកបរទៅភ្នំពេញនឹងត្រូវកាត់បន្ថយពេលវេលាពាក់កណ្ដាល នៅពេលស្ពានថ្មីសាងសង់នៅអ្នកលឿង*

6. *ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា ក្នុងឆ្នាំ ២00៦ របស់មូលនិធិអាស៊ី និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនៅកម្ពុជា បានវាស់វែងអាជីវកម្មចំនួន ៥00 នៅក្នុងខេត្តក្រុងចំនួនដប់: ភ្នំពេញ សៀមរាប កំពត បាត់ដំបង កំពង់ចាម កណ្ដាល បន្ទាយមានជ័យ ស្វាយរៀង កំពង់ឆ្នាំង និងក្រុងព្រះសីហនុ ។*

# តើហេតុអ្វីជ្រើសរើសយកខេត្តស្វាយរៀង?







## ថ្លៃសុំសិទ្ធិចូលវិនិយោគទាប

ខេត្តស្វាយរៀងបានបង្កើតប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មមួយ ដ៏មានប្រសិទ្ធភាពបំផុតនៅក្នុងប្រទេសដែលតំណាងដោយថ្លៃអាជ្ញាប័ណ្ណទាប លក្ខខណៈមានកំណត់សំរាប់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតពិសេស ហើយជាទូទៅមានរយៈពេលចុះបញ្ជីលឿនបំផុត ។ យើងធ្វើអ្វីគ្រប់យ៉ាងតាមដែលអាចធ្វើបាន ដើម្បីធានាថាការចាប់ផ្ដើមសហគ្រាសរបស់អ្នក នៅក្នុងខេត្តរបស់យើងប្រព្រឹត្តទៅដោយគ្មានបញ្ហា និងប្រកបដោយប្រសិទ្ធភាព ។

| សូចនាករអំពីថ្លៃសុំសិទ្ធិចូលវិនិយោគ | ថ្ងៃ* | ថ្លៃ $* |
|---|---|---|
| លិខិតបញ្ជាក់ការចុះបញ្ជីនៅក្នុងខេត្ត | 20 | 10 |
| អាជ្ញាប័ណ្ណប្រតិបត្តិការនៅក្នុងខេត្ត | 9 | 8 |
| លិខិតបញ្ជាក់ការបង់ពន្ធប៉ាតង់ | 10 | 10 |

*ជាមធ្យម

## ការការពារបទល្មើសល្អបំផុត

ខេត្តស្វាយរៀងទទួលបានចំណាត់ថ្នាក់លេខមួយទូទាំងប្រទេស ផ្នែកការពារបទល្មើសសំរាប់អាជីវកម្ម ។ សមាមាត្រនៃក្រុមហ៊ុនដែល ទទួលរងការខាតបង់ដោយសារបទល្មើស និងតំលៃនៃការខាតបង់ មានកំរិតទាបជាងគេបំផុតនៅកម្ពុជា ។

| សូចនាករការពារបទល្មើស | |
|---|---|
| ក្រុមហ៊ុនដែលមិនទទួលរងការបំពាន (%) | 93 |
| ការខាតបង់របស់ក្រុមហ៊ុនដែលមិនទទួលរងការបំពាន (ជាមធ្យម $) | 50 |

យើងមានមោទនភាពណាស់ ដែលបានបង្កើតបរិយាកាសមួយ ដែលគាំទ្រដល់តម្រូវការនានា និងផ្ដល់នូវប្រយោជន៍អាជីវកម្មរបស់យើង ហើយយើងទន្ទឹងរង់ចាំស្វាគមន៍ចំពោះអាជីវកម្មថ្មៗប្រឌិតថ្មីៗ ដែលកំពុងនឹងដំណើរការបន្ថែមទៀតមកដល់ខេត្តរបស់យើង ។

### ៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខគេ

តំបន់បាវិតនៃខេត្តស្វាយរៀង ដែលទីតាំងយុទ្ធសាស្ត្ររបស់ខ្លួននៅជាប់នឹងព្រំប្រទល់វៀតណាម ត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជាថា ជាតំបន់អាទិភាពមួយសំរាប់ការវិនិយោគនៅក្នុងវឌ្ឍនភាពឧស្សាហកម្ម ។ ទីតាំងនេះបង្កើតបានជាតំបន់សេដ្ឋកិច្ចពិសេស (SEZs) ។ តំបន់សេដ្ឋកិច្ចពិសេសទាំងនេះ ធ្វើឱ្យកិត្តិស័ព្ទខេត្តរបស់យើងកាន់តែប្រសើរថែមទៀតថាជាអ្នកផ្ដល់ បរិយាកាសអាជីវកម្មល្អបំផុត ។

តំបន់សេដ្ឋកិច្ចពិសេសមួយកំពុងប្រតិបត្តិការ ស្របពេលតំបន់សេដ្ឋកិច្ចពិសេសពីរទៀតត្រូវបានអនុម័ត ។ វិនិយោគិននៅក្នុងតំបន់សេដ្ឋកិច្ច ទាំងនេះមានកម្មករ ៨,000 នាក់មកធ្វើការផ្នែកផលិត និងនាំចេញស្បែកជើង និងស្រោមជើង វាយនភណ្ឌ កង់ ពូក ខ្មៅយ គ្រឿងដែក ថ្នាំលាប និង ឧបករណ៍កុំព្យូទ័រជាដើម ។

**កម្ពុជា-ខេត្តស្វាយរៀង រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុងបាងកក និង ហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ

ក្រុមហ៊ុនចំនួនប្រាំបី បានរើទៅដាក់ទីតាំងនៅតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេនដែលក្នុងនោះក្រុមហ៊ុនចំនួនប្រាំ បានចាប់ផ្ដើមប្រតិបត្តិការ ។ ស្បែកជើង និងស្រោមជើង Kingmaker របស់តៃវ៉ាន់ជាឧស្សាហកម្មធំជាងគេមួយនៅលើពិភពលោក ជាវិនិយោគិនសំខាន់ និងជាផលិតករ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន Manhattan SEZ ។ នៅក្នុងរយៈពេល ៣ ឆ្នាំ គេរំពឹងថា បង្កើនផលិតកម្ម ប្រចាំឆ្នាំនៅមេនហាតធេន រហូតដល់ ៣ លានគូរ ដោយប្រើប្រាស់កម្មករ ៥,000 នាក់ ។

រយៈមួយម៉ោងពីទីក្រុងហូជីមិញ តំបន់សេដ្ឋកិច្ចទាំងនេះផ្ដល់នូវ:

- ការិយាល័យរដ្ឋបាល តំបន់សេដ្ឋកិច្ចពិសេសនៅតាមច្រកព្រំដែនតែមួយ និងនៅក្នុងតំបន់ផ្ទាល់សម្រាប់រាល់ការរត់ការ និង កិច្ចព្រមព្រៀង ។
- អំឡុងពេលក្រុមហ៊ុនមិនចាំបាច់បង់ពន្ធចន្លោះពេលពី ៣ទៅ៩ ឆ្នាំ
- លើកលែងពន្ធនាំចូលពេញលេញ
- ពុំមានពន្ធនាំចេញ
- កុងតឺន័រឆ្លងកាត់ព្រំដែនមិនបិតនៅក្រោមការត្រួតពិនិត្យរបស់គយផ្សេងទៀត
- ហេដ្ឋារចនាសម្ព័ន្ធថ្នាក់ពិភពលោក

តំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន មានចំងាយតែ ៦៥គ.ម ពីចំណតយន្តហោះទីក្រុងហូជីមិញ និងមានចំងាយ ៨០គ.ម ពីកំពង់ផែ ដោយផ្ដល់ការចំណាយទាប ដើម្បីទទួលបានការដឹកជញ្ជូនតាមដីគោក សមុទ្រ និង អាកាស ។

# តើហេតុអ្វីជ្រើសរើសយកខេត្តស្វាយរៀង?






| ការចំណាយទៅលើអាជីវកម្មនៅតំបន់សេដ្ឋកិច្ច ម៉េនហាតថេន Manhattan SEZ | តម្លៃ |
|---|---|
| ដីឧស្សាហកម្ម (ជួល 99 ឆ្នាំ) | $25-30/ម² |
| ការជួលរោងចក្រ | $2.50/ម²/ខែ |
| អគ្គិសនី | $0.1262/គីឡូវ៉ាត់ម៉ោង |
| ការផ្គត់ផ្គង់ទឹក | $0.15/តោន |
| លូទឹកស្អុយ និងប្រព្រឹត្តកម្មទឹកកខ្វក់ | $0.25/តោន |
| ថ្លៃថែទាំហេដ្ឋារចនាសម្ព័ន្ធ | $0.04/ម²/ខែ |

## ៤. សក្តានុពលវិស័យទេសចរណ៍

ជារៀងរាល់ខែមានភ្ញៀវទេសចរណ៍ចំនួន ៣០,០០០ នាក់ មកពីវៀតណាមចូលមកខេត្តស្វាយរៀង ។ ដោយសារប្រទេសកម្ពុជានៅតែបន្តអភិវឌ្ឍន៍វិស័យទេសចរណ៍របស់ខ្លួនថែមទៀតនោះ ចំនួនអ្នកធ្វើដំណើរមកពីប្រទេសវៀតណាមដែលចូលមកកាន់ខេត្តរបស់យើងរំពឹងថានឹងមានការកើនឡើងគួរឱ្យកត់សំគាល់ ។

ខេត្តស្វាយរៀង គឺជាច្រកទ្វារពីប្រទេសវៀតណាមចូលមកកាន់កម្ពុជា ។ ក្រុមហ៊ុនម៉ាឡេស៊ី CVI Resort មានផែនការវិនិយោគដី ១០០លាន ដុល្លារដើម្បីសាងសង់សណ្ឋាគារ លំដាប់ផ្កាយប្រាំ វាលវាយកូនហ្គោល មជ្ឈមណ្ឌលពាណិជ្ជកម្ម និងតំបន់កំសាន្តនៅក្នុងខេត្តស្វាយរៀង នៅតាមបណ្តោយព្រំដែនទល់នឹងប្រទេសវៀតណាម ។ លើសពីនេះទៅទៀត អាជ្ញាធរក្នុងតំបន់ថ្មីៗនេះយើងបាន លៃលកដី ១០ ហិកតា ដែលជាអចលនទ្រព្យដ៏ថ្លៃថ្លា ដើម្បីអភិវឌ្ឍន៍តំបន់ទេសចរណ៍ ដើម្បីលើកទឹកចិត្តឱ្យភ្ញៀវទេចរណ៍នៅលេងកំសាន្តបានកាន់តែយូរជាងមុននៅស្វាយរៀង នេះមុននឹងភ្ញៀវទេសចរណ៍ទាំងនោះបន្តដំណើររបស់ខ្លួនទៅកាន់ក្រុងភ្នំពេញ ។ តំបន់ទេសចរណ៍នោះ មានចម្ងាយត្រឹមតែ ៧គ.ម ប៉ុណ្ណោះ ពីទីរួមខេត្តស្វាយរៀងស្ថិតនៅតាមបណ្តោយទន្លេ ហើយរួមមានទាំងប្រាសាទប្រវត្តិសាស្ត្រទៀតផង ដែលជាទីកន្លែងដ៏ល្អឥតខ្ចោះ ដែលត្រូវចំណាយពេលពីរបីថ្ងៃនៅទីនេះមុននឹងបន្តដំណើរចូលទៅក្នុងរាជធានី ។

ដើម្បីបន្តលើកទឹកចិត្តភ្ញៀវទេសចរណ៍ក្នុងតំបន់ កាស៊ីណូចំនួន ៧ នៅទីនេះ ក៏កំពុងតែផ្តល់នូវប្រជាប្រិយភាពជាមួយនឹងភ្ញៀវទេសចរណ៍វៀតណាមរបស់យើង ។

ជាមួយគ្នានេះដែរ ទំនៀមទំលាប់ និងប្រពៃណី ពិធីបុណ្យទាន និងបុណ្យសាសនាផ្សេងៗ គឺជាកេរ្តិ៍តំណែលវប្បធម៌មួយចំនួន ដែលភ្ញៀវទេសចរណ៍អាចចូលរួមកំសាន្តបាននៅក្នុងខេត្តនេះ ។

យើងប្តេជ្ញាបន្តជំរុញឱ្យមានការវិនិយោគបន្ថែមទៀត នៅក្នុងវិស័យទេសចរណ៍ក្នុងមូលដ្ឋាន និងឧស្សាហកម្មផ្នែកសណ្ឋាគារ និងផ្នែកបដិសណ្ឋារកិច្ច ។

## ៥. កម្លាំងពលកម្មដែលមានការអប់រំ

ប្រជាពលរដ្ឋរបស់ខេត្តយើងចំនួន ៥៥០ ០០០ នាក់ គឺជាកម្លាំងការងារ ដែលមានភាពស្វាហាប់ ។ ដោយឡែកប្រជាពលរដ្ឋរបស់យើង មានកម្រិតយល់ដឹង និងការអប់រំច្រើនជាងខេត្តដទៃទៀតជាច្រើននៅកម្ពុជា ។ កម្លាំងការងាររបស់យើងនៅក្មេង ខំប្រឹងធ្វើការងារ និងមានចំណេះដឹង ។

### ប្រជាសាស្ត្រអនុគ្រោះ[7]




ការចំណាយទៅលើការអប់រំនៅបឋមសិក្សា ដែលជាផ្នែកមួយនៃផលិតផលក្នុងស្រុកសរុប (GDP) បានកើនឡើងគួរឱ្យកត់សំគាល់នៅក្នុងប្រទេសកម្ពុជា ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបច្ចុប្បន្ននេះមានកំរិតប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសថៃដែរ ។ ខេត្តស្វាយរៀងមិនឈប់ត្រឹមនេះទេ ។ រដ្ឋាភិបាលមានផែនការបន្តបង្កើនការចំណាយទៅលើការអប់រំបន្តទៀត ។

សាកលវិទ្យាល័យស្វាយរៀង ជាសាកលវិទ្យាល័យដំបូងគេ បើកនៅខែ មករា ឆ្នាំ ២០០៦ នៅក្នុងខេត្តស្វាយរៀង ។ បច្ចុប្បន្ននេះ សាកលវិទ្យាល័យនេះ មាននិស្សិតជាង ១៨០០នាក់ និស្សិតជាច្រើនជាប់អាហារូបករណ៍ ប៉ុន្តែនិស្សិតជាង ៥០០នាក់ រៀនបង់ថ្លៃសិក្សាពេញ ។

កម្លាំងការងាររបស់ខេត្តស្វាយរៀង ត្រូវបានបង្កើតឡើងដោយមាន ២៣% បម្រើការងារនៅក្នុងវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ។

សូចនាករមួយ នៃភាពទាក់ទាញរបស់ខេត្តស្វាយរៀងគឺ ចំណាកស្រុកនៅក្នុងខេត្តមានកម្រិតខ្ពស់ ។វាជាខេត្តមួយក្នុងចំណោមខេត្តពីរ ឬបីរបស់កម្ពុជាដែលមានចំណាកស្រុកក្នុងអន្តរខេត្តជាបណ្តាញវិជ្ជមាន ។

យើងមានមោទនភាព ដែលយើងមានធនធានមនុស្សនាំមុខគេ ក្នុងការគាំទ្រដល់អាជីវកម្មរបស់យើង ហើយយើងជឿជាក់ថា នេះជាឧត្តមភាពក្នុងការប្រកួតប្រជែងគន្លឹះមួយរបស់យើង សូមឱ្យប្រជាពលរដ្ឋរបស់យើងជួយដល់សហគ្រាស របស់អ្នកឱ្យរីកចំរើនថែមទៀត ។

---

*7. វិទ្យាស្ថានជាតិស្ថិតិ ជម្រឿនប្រជាជននៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៤ ។*






### ៦. អគ្គិសនីមានលក្ខណៈប្រកួតប្រជែង និងអាចទុកចិត្តបាន

ខេត្តស្វាយរៀង ទទួលបានការផ្គត់ផ្គង់ អគ្គិសនីពីប្រភពមួយចំនួន រួមទាំង ក្រុមហ៊ុនផលិតថាមពលអគ្គិសនីឯកជនចំនួន ១៤ ។ នៅក្នុងទីរួមខេត្តស្វាយរៀង ក្រុមគ្រួសារ ៩៧% មានអគ្គិសនីប្រើប្រាស់ ដែលគិតជាមធ្យមប្រើប្រាស់អស់ ៣១ គីឡូវ៉ាត់ក្នុងមួយខែ ។ គួរឱ្យកត់សំគាល់នោះ ស្រុកចំនួន ៤ នៅក្នុងខេត្តនេះមានតបណ្ដាញអគ្គិសនីមកពីប្រទេសវៀតណាម ដែលជាប្រភពថាមពលដែលមានតម្លៃថោក សំខាន់ជាងនេះទៅទៀតអាចជឿជាក់បានសំរាប់អាជីវកម្មរបស់អ្នក ។ ថាមពលអគ្គិសនីនាំចូលពីវៀតណាម តម្លៃ ៦៥០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ។

គេរំពឹងថា ការនាំចូលអគ្គិសនីពីវៀតណាមនឹងកើនឡើងនៅអំឡុងមួយឬពីរឆ្នាំទៀតហើយស្រុកចំនួនពីរបន្ថែមទៀត នឹងចាប់ផ្តើមប្រើប្រាស់អគ្គិសនីវៀតណាមនៅឆ្នាំ២០០៩ ។

## ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត

ភាពជោគជ័យរបស់យើងចំពោះការគាំទ្រវិស័យអាជីវកម្មដ៏ខ្លាំងក្លា និងយ៉ាងសកម្មបានធ្វើឱ្យខេត្តស្វាយរៀងជាគោលដៅទីមួយសំរាប់សហគ្រាសនានានៅក្នុងប្រទេស ដែលរួមមានដូចជា:

| សកម្មភាព | ចំនួនសហគ្រាស | ចំនួននិយោជិក |
|---|---|---|
| តម្បាញ កាត់ដេរ ស្រោមជើង និងស្បែកជើង | ៧ | ៥,០០០ |
| រោងចក្រថ្នាំលាប | ១ | ៤០ |
| ការកែច្នៃដំឡូងមី | ១ | គ្មាន |
| រោងចក្រផលិតកង់ | ២ | ១,៥១២ |
| គ្រឿងកុំព្យូទ័រ | ១ | ៩១ |
| សំណង់ | ៧ | គ្មាន |
| ពាណិជ្ជកម្ម | ៤២ | គ្មាន |
| សេវាផ្សេងៗ | ១០ | គ្មាន |

ទិន្នផលដែលមកពីអាជីវកម្មទាំងនេះភាគច្រើន ត្រូវនាំចេញទៅ ប្រទេសវៀតណាម ។

តំបន់ឧស្សាហកម្មរបស់យើងកំពុងតែអភិវឌ្ឍន៍ ។ រោងចក្រកាត់ដេរចំនួនប្រាំពីរប្រតិបត្តិការនៅក្នុងខេត្តនេះ មានរោងចក្រចំនួនបួន ប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅបាវិត និងរោងចក្រចំនួនបីនៅកន្លែងផ្សេងទៀតនៅក្នុងខេត្ត ។ នៅដើមឆ្នាំ២០០៨ ក្រុមហ៊ុន Kova Paint Group បានបើករោងចក្រថ្នាំលាបដំបូងគេនៅកម្ពុជានៅខេត្តស្វាយរៀង ។ រោងចក្រនេះជាសម្ព័ន្ធអាជីវកម្មរវាងវិនិយោគិនវៀតណាម និងសឹង្ហបុរី ។

អាជីវកម្មធុនតូច ប្រតិបត្តិការនៅក្នុងខេត្តរបស់យើង បានចុះបញ្ជីអាជីវកម្មនៅខេត្តរបស់យើងចំនួនជិត ៧៥០ នៅមន្ទីរពាណិជ្ជកម្មខេត្ត ។ លើសពីនេះទៅទៀត មីក្រូសហគ្រាសប្រហែល ៣០០០សហគ្រាស នៅក្នុងខេត្តស្វាយរៀង ចូលរួមក្នុងសកម្មភាពនានា ដូចជា:

- រោងម៉ាស៊ីនកិនស្រូវ
- ការជួសជុលគ្រឿងចក្រ និងម៉ូតូ
- ការលក់ដុំ និងលក់រាយ
- ឱសថស្ថាន និង
- សេវាម្ហូបអាហារ និងបដិសណ្ឋារកិច្ចផ្សេងៗ

## ឱកាសអាជីវកម្ម

ខេត្តរបស់យើងផ្តល់ឱកាសជាច្រើនសំរាប់អាជីវកម្មថ្មីៗ ដែលបង្ហាញយ៉ាងច្បាស់ដោយក្រុមហ៊ុននានាជាច្រើនប្រភេទ ដែលបានប្រតិបត្តិការនៅទីនេះស្រាប់ រាប់តាំងពីក្រុមហ៊ុនកសិកម្ម និង កសិ-ពាណិជ្ជកម្មទៅជាក្រុមហ៊ុនផលិតធុនស្រាល ។ យើងមើលឃើញឱកាសសំខាន់ៗ សំរាប់អាជីវកម្ម ដើម្បីទាញយកផលប្រយោជន៍កំលាំងប្រកួតប្រជែងតាមរយៈការវិនិយោគទុនបន្ថែម ទៀតនៅក្នុងវិស័យ:

- **កសិកម្ម** – មានដីសម្បទានសំរាប់ឱ្យវិនិយោគិន ផលិតផលកសិកម្មជាច្រើន រួមទាំងដំណាំកៅស៊ូផងដែរ ។ ក្រុមហ៊ុនមួយចំនួនមកពីគុយវ៉ែត បច្ចុប្បន្ននេះ កំពុងវាយតម្លៃទៅលើឱកាសដាំដំណាំ ដំឡូងមី ស្រូវ និងអំពៅ ។
- **ការកែច្នៃម្ហូបអាហារ** – ខេត្តរបស់យើង មានទំនិញកសិកម្មចំបង ជាច្រើនដែលរួមផ្សំជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដ៏រឹងមាំ ដើម្បីធ្វើឱ្យមានការកែច្នៃ (សំរាប់ទីផ្សារក្នុងស្រុកនិងនាំចេញ ។ ជាពិសេសយើងមាន មាន់ទា ជ្រូក ជាច្រើនសន្ធឹកសន្ធាប់ ដូច្នេះយើងមើលឃើញពីសក្តានុពលនៃការកែច្នៃសាច់ [8] ។
- **ការផលិតធុនស្រាល** – រួមទាំងកាត់ដេរសំលៀកបំពាក់ និងស្បែកជើង និងស្រោមជើង ។ យើងមានកម្លាំងពលកម្មជាច្រើន ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ និងបរិយាកាសអាជីវកម្មដែលមានអំណោយផល ។
- **ទេសចរណ៍ និងបដិសណ្ឋារកិច្ច** – ដូចមានរៀបរាប់ខាងលើភ្ញៀវទេសចរណ៍ ដែលមកពីប្រទេសវៀតណាម នឹងបន្តមានការកើនឡើង ។ យើងស្វែងរកវិនិយោគិនដែលនឹងជួយដល់យើងក្នុងការចាប់យកឱកាសរីកចំរើនទាំងនេះបន្ថែមទៀត ។

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ

ទោះបីជាយើងមានមោទនភាពចំពោះស្នាដៃនានារបស់យើងក៏ដោយ ក៏យើងនៅតែពង្រឹងនិងខិតខំទាក់ទាញផ្នែកវិនិយោគឱ្យកាន់តែមានភាពប្រសើរថែមទៀតដែរ ។ យើងនៅតែសកម្មក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មរបស់យើង និងទាក់ទាញសហគ្រាសអាជីវកម្មឈានមុខគេឱ្យចូលមកខេត្តរបស់យើង ។ ការអភិវឌ្ឍន៍សំខាន់ៗមួយចំនួននៅក្រោមវិធីសាស្ត្រ រួមមានដូចតទៅ:

8. *ជាឧទាហរណ៍: កម្ពុជានាំចូលសាច់ជ្រូក ៣០០ តោនក្នុងមួយឆ្នាំ ។ យើងមានវិសាលភាពសំរាប់ឱ្យផលិតកម្មក្នុងស្រុក ជំនួសការនាំចូលទាំងនេះ ។*

- បន្តអភិវឌ្ឍតំបន់បារិតឱ្យក្លាយទៅជាតំបន់កែច្នៃឧស្សាហកម្ម[9] ។
- អភិវឌ្ឍជាបន្តនូវដំណោះស្រាយបញ្ហាទឹក ដែលមានភាពចាំបាច់ដល់ការបង្កើនទិន្នផលកសិកម្ម ។ ធនាគារអភិវឌ្ឍន៍អាស៊ី គ្រោងនឹងផ្តល់ហិរញ្ញប្បទានដល់គម្រោងធារាសាស្រ្តធំមួយនៅតាមបណ្តោយព្រំដែនវៀតណាម ។
- អភិវឌ្ឍបន្ថែមទូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងគមនាគមន៍ ។

ក្រៅពីនេះ វិនិយោគិនទទួលអត្ថប្រយោជន៍ពីយុទ្ធសាស្រ្តសមាហរណកម្មពាណិជ្ជកម្ម វិទិ្ធយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ នៅក្រោមកម្មវិធីនេះ ផលិតផលនៅក្នុងខេត្តស្វាយរៀងជាច្រើន ទទួលបានការគាំទ្របន្ថែមទៀត ។ផលិតផលដែលកំណត់អត្តសញ្ញាណដោយយុទ្ធសាស្ត្រនេះ រួមមានទាំង ដំណាំជ័រកៅស៊ូ ការចិញ្ចឹមសត្វ កាត់ដេរសំលៀកបំពាក់ ការផលិតធុនស្រាល និងទេសចរណ៍ ។ ជំនួយត្រូវបានផ្តល់ឱ្យក្រុមហ៊ុនដែលបាន និងកំពុងប្រតិបត្តិការលើវិស័យសំខាន់ៗទាំងអស់នេះ រួមបញ្ចូលទាំងការសំរបសំរួលពាណិជ្ជកម្មនិងការផ្សព្វផ្សាយការវិនិយោគទុន ការកែទំរង់ផ្នែកច្បាប់ និងការកសាងសមត្ថភាពលើការគ្រប់គ្រង និងជំនាញក្នុងស្រុក ។

ដៃគូអភិវឌ្ឍន៍មួយចំនួន កំពុងជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តស្វាយរៀង ក្នុងឧស្សាហកម្មសំខាន់ៗ:

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
|---|---|---|
| គម្រោងពង្រីកកសិកម្មកម្ពុជា-អូស្ត្រាលី ដំណាក់កាលទី II (CAAEP II) | AusAID | កសិកម្ម |
| គម្រោងកែលំអគុណភាពកសិកម្ម | AusAID | ស្រូវ ផ្លែឈើ និង បន្លែ |
| គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូចនិងខ្នាតមធ្យមនៅកម្ពុជា (Cambodia MSME) | USAID | ការចិញ្ចឹមសត្វ វារីវប្បកម្ម កែច្នៃកសិកម្ម និង ឡឥដ្ឋ-ក្បឿង |
| ការអភិវឌ្ឍន៍ទីផ្សារ ផលិតករខ្នាតតូច | CIDA / CIGAR | ផ្លែឈើ និងបន្លែ |

## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

សំរាប់ព័ត៌មានបន្ថែម ស្តីអំពីឱកាសវិនិយោគ និងការអភិវឌ្ឍន៍នៅក្នុងខេត្តស្វាយរៀង សូមទាក់ទង:

**លោក ឈិន សាធាន**
នាយរងខុទ្ទកាល័យ ខេត្តស្វាយរៀង
(855) 012 949 408
(855) 016 915 506

**www.cambodiainvestment.gov.kh**
**www.investincambodia.com**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គណកម្មការវិនិយោគកម្ពុជា
ទូរស័ព្ទ: (855) 23 981 154
www.cambodianinvestment.gov.kh
អ៊ីមែល: CDC.CIB@online.com.kh

វិទ្យាស្ថានជាតិស្ថិតិ:
www.nis.gov.kh

### ក្រសួងនានា

តំបន់សេដ្ឋកិច្ចពិសេស:
http://www.cambodiasez.gov.kh/index.htm
ក្រសួងពាណិជ្ជកម្ម:
www.moc.gov.kh
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:
www.mef.gov.kh
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល:
www.mine.gov.kh
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:
www.mlv.gov.kh
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់:
www.mlmupc.gov.kh
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍:
www.mptc.gov.kh
ក្រសួងសាធារណការណ៍ និងដឹកជញ្ជូន:
www.mpwt.gov.kh
ក្រសួងទេសចរណ៍:
www.mot.gov.kh
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:
www.maff.gov.kh

### ផ្សេងៗ

សមាគមក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់កម្ពុជា:
www.gmac-cambodia.org
វេទិកាវិស័យឯកជន-រដ្ឋាភិបាល:
www.cambodia-gpsf.org

| ស្ថានភាពទូទៅខេត្តស្វាយរៀង | |
|---|---|
| ចំនួនប្រជាជន: | 550,795 |
| អាយុពី 15-64: | 58% |
| ទំហំការងារក្នុងវិស័យកសិកម្ម: | 76% |
| លំដាប់ថ្នាក់ភាពក្រីក្ររបស់ខេត្ត: | 13/24 |
| ផ្ទៃដី: | 2,966 km² |
| ដង់ស៊ីតេប្រជាជន: (% ចំនួនប្រជាជនជាមធ្យម) | 234% |
| ចំនួនស្រុក: | 7 |
| ចំនួនឃុំ: | 80 |

| ស្ថានភាពដីក្នុងខេត្តស្វាយរៀង |
|---|
| ប្រភេទ: ភាគច្រើនជាប្រភេទដីជូរ ខ្លះជាដីប្រផេះល្បាប់ និងជាដីជាំទឹកជាំដុះ |
| កម្រិតជីវជាតិ: មធ្យម |

9. *រដ្ឋសភាជាតិ បានអនុម័តឱ្យអភិវឌ្ឍបារិតឱ្យទៅជាទីក្រុងមួយរបស់ខេត្តស្វាយរៀង ។*

| អត្រាពន្ធនៅកម្ពុជា | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាប្រាក់ លើក-ទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអតិបរមា | | 1% ប្រាក់ចំណូល |
| ពន្ធកាត់ទុក | | 15% |
| ចំណូលបានមកពីការជួលអលនទ្រព្យ | | 10% |
| ការទូទាត់ចំពោះមនុស្សចំណូលស្រុក | | 14% |
| | | |
| ពន្ធលើប្រាក់ខែ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| មនុស្សចំណូលស្រុក | អត្រាថេរ | 20% |
| ពន្ធផលប្រយោជន៏បន្ទាប់បន្សំ | | 20% |
| តម្លៃបន្ថែមលើពន្ធ | | 10% |
| | នាំចេញ | 0% |
| ពន្ធផ្ទេរអចលនទ្រព្យ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា | 2005 | 2006 | 2007 | 2008f | 2009f |
|---|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 7.5 | 7.0 |
| កំណើននាំចេញ (%) | 12.6 | 19.2 | 8.1 | 5.6 | 8.5 |
| នាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 65.7 | 66.1 |
| FDI ($m) | 375 | 475 | 598 | 660 | 759 |
| វិនិយោគទុនបរទេស (% GDP) | 6.0 | 6.5 | 6.9 | 6.7 | 6.8 |

## ចំណាយអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| ភ្នំពេញ | $350-$2,000 |
| ដីពាណិជ្ជកម្ម | $30-$200 |
| តំបន់ផ្សេង | $4-$50 |
| ជនបទ | $0.50-$5 |

| ដីសំរាប់ការិយាល័យ | តម្លៃជួលក្នុងមួយខែ |
|---|---|
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| | |
| ប្រាក់ជួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ប្រាក់ជួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| តម្លៃអគ្គិសនីនៅភ្នំពេញ (excl. SEZs) | | |
|---|---|---|
| ឧស្សាហកម្ម | គីឡូវ៉ាត់ម៉ោង/ខែ | តម្លៃ(រៀល/គីឡូវ៉ាត់) |
| | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| | | |
| ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម | | $0.32/គ.ក្រ |

| តម្លៃពលកម្ម | ប្រាក់ខែ $ ក្នុងមួយខែ |
|---|---|
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | 1,000-1,500 |
| អ្នកគ្រប់គ្រងកណ្តាល | 500-1,000 |
| អ្នកគ្រប់គ្រងកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ជំនួយការ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាមទ្វារ | 50-80 |
| កម្មករ | 50-80 |
| ប្រាក់ឈ្នួលអប្បបរមារបស់កម្មករកាត់ដេរ | 60 |

# ខេត្តស្វាយរៀង

# សក្តានុពលវិនិយោគ




Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com